ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**

សំណុំរឿងរដ្ឋប្បវេណី លេខ១៥៩ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០

សាលក្រមរដ្ឋប្បវេណីលេខ**៧៦/០៥ "ក"** ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

**សាលក្រមចំពោះមុខដើមចោទ និងចំពោះមុខចុងចម្លើយ**

កាលបរិច្ឆេទ នៃការបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០។

កាលបរិច្ឆេទនៃការប្រកាសសាលក្រម ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ នៅសាលាដំបូងខេត្តព្រះសីហនុ។

**កម្មវត្ថុបណ្ដឹង:** ប្ដឹងសុំលែងលះ។

### សមាសភាពជំនុំជម្រះ

**-ឯកឧត្តម [redacted] ជាចៅក្រមជំនុំជម្រះ**

**-លោកស្រី [redacted] ជាក្រឡាបញ្ជីសវនាការ**

### ១. ភាគីដែលបង្ហាញខ្លួនជាអាទិ៍:

- ដើមចោទឈ្មោះ [redacted] **ស្រស់** ភេទស្រី អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន មាន [redacted] ។ មានលោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ [redacted] ។
- ចុងចម្លើយឈ្មោះ [redacted] **ឈឿន** ភេទប្រុស អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងថតរូប មាន [redacted] ។

### <u>អង្គហេតុ និងចំណុចវិវាទ</u>

### ២. សាលក្រមដែលទាមទារដោយដើមចោទ:

- សុំលែងលះពីឈ្មោះ [redacted] **ឈឿន** ។
- សុំសិទ្ធិគ្រប់គ្រង ចិញ្ចឹមបីបាច់ និងថែរក្សាកូនឈ្មោះ [redacted] **ហ៊ងអី** ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០១០ និងកូនឈ្មោះ [redacted] **សៀនទ័រ** ភេទប្រុស កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ។
- សុំឱ្យចុងចម្លើយទទួលបន្ទុករ៉ាប់រងចំពោះបំណុលខ្ចីធនាគារចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិក) ។



Scanned with CamScanner

- សុំសិទ្ធិគ្រប់គ្រងលើដីមួយកន្លែង ទំហំ ១០០ម៉ែត្រការ៉េ ដែលមានទីតាំងនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៨៧២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ។
- ប្រាកប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

## ៣. ការពន្យល់រឿងក្តីត្រួសៗ

### ក. អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុបញ្ជាក់ការទាមទារ

ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមអក្សារដ្ឋេកអានបញ្ជាក់តាំបុត្រអាពាហ៍ពិពាហ៍លេខ៨៧ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩។ ការរស់នៅជាមួយគ្នាដើមចោទ និងចុងចម្លើយមានកូនចំនួន០២នាក់គឺ ឈ្មោះ [redacted] **ហ៊ង់អី** ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ និងកូនឈ្មោះ [redacted] **សៀនទ័រ** ភេទប្រុស កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ។ ក្នុងចំណងអាពាហ៍ពិពាហ៍ ដើមចោទ និងចុងចម្លើយបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ១០,០០០$(មួយម៉ឺនដុល្លារអាមេរិក) ដែលប្រាក់នេះ គឺបំរុងយកមកសាងសង់ផ្ទះ ប៉ុន្តែចុងចម្លើយបែរជាយកទៅប្រើការអ្វីផ្សេង ។ មួយវិញទៀត ចំពោះដីមួយកន្លែងទំហំ ១០០ម៉ែត្រការ៉េ ដែលមានទីតាំងនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ គឺដើមចោទ និងចុងចម្លើយបានអះអាងថាជាដីរបស់ម្តាយ។ ក្រោយពីរស់នៅជាមួយគ្នាច្រើនឆ្នាំកន្លងមក ក៏ចាប់ផ្តើមរស់នៅមិនចុះសម្រុងគ្នា ចេះតែឈ្លោះប្រកែកគ្នា ហេតុនេះហើយទើបថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ដើមចោទក៏បានដាក់ពាក្យបណ្តឹងប្តឹងលែងលះពីចុងចម្លើយតែម្តង។

### ខ. ភស្តុតាងថតចម្លងដែលដាក់ដោយដើមចោទ៖

- សំបុត្រអាពាហ៍ពិពាហ៍ លេខ៨៧ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ។
- តារាងកាលវិភាគសងប្រាក់ របស់[redacted] ។
- សៀវភៅគ្រួសារ លេខ ០២០៧៥៤ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ។
- សំបុត្របញ្ជាក់កំណើតលេខ៣៨៣ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ។
- សំបុត្របញ្ជាក់កំណើតលេខ៥០៩ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១២ ។
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១៨០១០១០៣-១៨៧២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩។
- លិខិតលក់ផ្តាច់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ។
- លិខិតបញ្ជាក់ការបង់ពន្ធប្រថាប់ត្រា ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ។

## ៤. ការអះអាងរបស់គាគី

### ក. ដើមចោទឈ្មោះ [redacted] ស្រស់ បានថ្លែងការណ៍ថា៖

នាងខ្ញុំសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម ៖

១.សុំលែងលះពីឈ្មោះ [redacted] ឈឿន ។

២.សុំសិទ្ធិគ្រប់គ្រង ចិញ្ចឹមបីបាច់ និងថែរក្សា កូនឈ្មោះ [redacted] **ហ័រអឺ** ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ និងកូនឈ្មោះ [redacted] **សៀនទ័រ** ភេទប្រុស កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ។

៣.សុំឱ្យចុងចម្លើយទទួលបន្ទុកវ៉ាប់រងចំពោះបំណុលខ្ចីធនាគារចំនួន១០,០០០$(មួយម៉ឺនដុល្លារអាមេរិក)។

៤.សុំសិទ្ធិគ្រប់គ្រងដីមួយកន្លែង ទំហំ ១០០ម៉ែត្រការ៉េ ដែលមានទីតាំងនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០ ១០១០៣-១៨៧២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

នាងខ្ញុំ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ តាមច្បាប់ នៅសាលាសង្កាត់លេខ៤។ ក្នុងចំណងអាពាហ៍ពិពាហ៍ យើងខ្ញុំមានកូនពីរនាក់ គឺឈ្មោះ [redacted] **ហ័រអឺ** ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ និងកូនឈ្មោះ [redacted] **សៀនទ័រ** ភេទប្រុស កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ។ នាងខ្ញុំសុំគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់ ប៉ុន្តែមិនមានទាមទារអាហារកិច្ចអ្វីទេ គឺសុំឱ្យតាមលទ្ធភាពរបស់ចុងចម្លើយទៅចុះ ។ ក្រោយមកក្នុងចំណងអាពាហ៍ពិពាហ៍ គឺកើតមានរឿងរកាំរកូស ឈ្លោះគ្នា ចេះតែរស់នៅមិនចុះសំរុងនឹងគ្នា ធ្វើឱ្យយើងខ្ញុំទាំងពីរនាក់ អស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នា ទើបនាងខ្ញុំ សម្រេចចិត្តលែងលះពីគ្នា ។ ក្នុងចំណងអាពាហ៍ពិពាហ៍ យើងខ្ញុំបានខ្ចីប្រាក់ពីគ្រឹះស្ថានមី [redacted] ចំនួន ១០,០០០$(មួយម៉ឺនដុល្លារអាមេរិក) ដែលប្រាក់នេះ គឺខ្ចីដើម្បីយកមកសាងសង់ផ្ទះ ប៉ុន្តែបែរជាចុងចម្លើយយកទៅប្រើការអ្វីផ្សេងទៅវិញ ដូច្នេះ នាងខ្ញុំស្នើសុំឱ្យចុងចម្លើយទទួលវ៉ាប់រងសងប្រាក់ចំនួន១០,០០០$ (មួយម៉ឺនដុល្លារអាមេរិក) ទៅឱ្យធនាគារវិញ ដោយខ្លួនឯង។ ចំពោះប្រាក់ប្រដាប់ក្តី សុំជាបន្ទុករបស់ចុងចម្លើយ ។ នាងខ្ញុំបានបែកលំនៅសង្វាសពីចុងចម្លើយតាំងពីខែមិថុនា ឆ្នាំ២០១៩ មកម្ល៉េះ ។

ចំពោះការសុំសិទ្ធិគ្រប់គ្រងដីមួយកន្លែង ដែលមានទំហំ ១០០ម៉ែត្រការ៉េ ដែលមានទីតាំងនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៨៧២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ គឺជាដីរបស់ម្តាយនាងខ្ញុំ ដោយកាលពីមុន នាងខ្ញុំ និងប្តីបំរុងទិញពីគាត់ ទើបបានធ្វើការផ្ទេរឈ្មោះមកយើងខ្ញុំទាំងពីរ ក្រោយមកនាងខ្ញុំ និងប្តីពុំមានប្រាក់ដើម្បីប្រគល់ឱ្យម្តាយ ដូច្នេះម្តាយនាងខ្ញុំស្នើសុំយកដីមួយកន្លែងនេះវិញ។

**ខ. ចុងចម្លើយឈ្មោះ [redacted] ឈឿន បានថ្លែងការណ៍ថា៖**

ខ្ញុំបាទយល់ព្រមលែងលះ ពីដើមចោទ, ខ្ញុំបាទយល់ព្រមប្រគល់សិទ្ធិ គ្រប់គ្រងកូន ឱ្យទៅដើមចោទ និងសុំផ្តល់អាហារកិច្ចឱ្យកូនតាមលទ្ធភាព។ ខ្ញុំបាទយល់ព្រមទទួលវ៉ាប់រងចំពោះបំណុលដែលខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ១០,០០០$(មួយម៉ឺនដុល្លារអាមេរិក)។ ចំពោះប្រាក់ប្រដាប់ក្តី ខ្ញុំបាទយល់ព្រមវ៉ាប់រង ។ ខ្ញុំបាទបានរៀបអាពាហ៍ពិពាហ៍ នឹងដើមចោទ តាំងពីឆ្នាំ



Scanned with CamScanner

២០០៩ មក ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ មូលហេតុលែងលះគ្នា ដោយសារតែការរស់នៅមិនចុះសម្រុងនឹងគ្នា ចេះតែរកាំរកូស ធ្វើឱ្យខ្ញុំបាទអស់មនោសញ្ចេតនាក្នុងការរួមរស់ជាប្តីប្រពន្ធនឹងគ្នា។ ក្នុងចំណងអាពាហ៍ពិពាហ៍ យើងខ្ញុំមានកូនពីរនាក់ គឺឈ្មោះ [redacted] **ហ័រអ៊ី** ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ និងកូនឈ្មោះ [redacted] **សៀនទ័រ** ភេទប្រុស កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ។ ខ្ញុំបាទបានបែកលំនៅសង្វាសពីដើមចោទតាំងពីខែមិថុនា ឆ្នាំ២០១៩ មកម្ល៉េះ ។ ខ្ញុំបាទឯកភាពនឹងការស្នើសុំសិទ្ធិគ្រប់គ្រងលើដីមួយកន្លែង ខាងលើនេះឱ្យទៅប្រពន្ធរបស់ខ្ញុំបាទ ព្រោះថាដីនេះ ជាដីរបស់ម្តាយក្មេកខ្ញុំបាទទេ ។

គ. **លោកស្រីមេធាវី** [redacted] **តំណាងដោយអាណត្តិឱ្យដើមចោទ អមដោយលោកមេធាវី** [redacted] **បានថ្លែងការណ៍ថា៖** នាងខ្ញុំឯកភាពនឹងសេចក្តីថ្លែងការណ៍របស់កូនក្តីនាងខ្ញុំ និងសុំឱ្យតុលាការមេត្តាសម្រេចចេញសាលក្រមដូចការទាមទាររបស់កូនក្តីនាងខ្ញុំ ដោយក្តីអនុគ្រោះ ។

## ៥. ចំណុចវិវាទ និងចំណុចគ្មានវិវាទ៖

**ក. ចំណុចវិវាទ (គ្មាន)។**

**ខ. ចំណុចគ្មានវិវាទ**

- ដើមចោទ និងចុងចម្លើយ ឯកភាពក្នុងការលែងលះគ្នា ។
- ដើមចោទ សុំសិទ្ធិគ្រប់គ្រងកូនពីរនាក់ គឺឈ្មោះ [redacted] **ហ័រអ៊ី** ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ និងកូនឈ្មោះ [redacted] **សៀនទ័រ** ភេទប្រុស កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ រីឯចុងចម្លើយឯកភាព ។
- ដើមចោទសុំឱ្យចុងចម្លើយទទួលរ៉ាប់រងបំណុលចំនួន ១០,000$ (មួយម៉ឺនដុល្លារអាមេរិក) រីឯចុងចម្លើយឯកភាព ។
- ដើមចោទសុំសិទ្ធិគ្រប់គ្រងដីមួយកន្លែង ទំហំ១០០ម៉ែត្រការ៉េ រីឯចុងចម្លើយឯកភាព ។
- ដើមចោទសុំឱ្យចុងចម្លើយរ៉ាប់រងប្រាក់ប្រដាប់ក្តី រីឯចុងចម្លើយឯកភាព ។

## <u>សំអាងហេតុ</u>

- **តាមលទ្ធផល នៃការសាកសួរ និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចប់សព្វគ្រប់ឃើញថា៖** ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាដោយមាន ចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដូចមានបញ្ជាក់សំបុត្រអាពាហ៍ពិពាហ៍លេខ៨៧ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩។ ដើមចោទ និងចុងចម្លើយអះអាងព្រមគ្នាថា ការរស់នៅជាមួយគ្នាពិតជាមិនចុះសម្រុងនឹងគ្នាប្រាកដមែន ធ្វើឱ្យគូភាគីអស់មនោសញ្ចេតនារួមរស់នៅជាមួយគ្នាតទៅទៀត គូភាគីឯកភាពលែងលះ ការពន្យារពេលយូរតទៅទៀតគ្មានលទ្ធផលល្អ ដូច្នេះគប្បីតុលាការសម្រេចឱ្យដើមចោទ និងចុងចម្លើយលែងលះពីគ្នាតាមការព្រមព្រៀង តាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី។



Scanned with CamScanner

- តាមការអះអាងរបស់ដើមចោទ និងចុងចម្លើយបញ្ជាក់ថា បានរស់នៅបែកលំនៅសង្វាសគ្នាតាំងពីខែមិថុនា ឆ្នាំ២០១៩ បើគិតមកដល់ពេលនេះគឺផុតរយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ ដែលកំណត់ក្នុងមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី ដូចនេះតុលាការនឹងមិនសម្រេចពីរយៈពេលនៃភាពមេម៉ាយរបស់ដើមចោទ នៅក្នុងសេចក្ដីសម្រេចនេះទេ។

- **អំពីអំណាចមេបា**

ដើមចោទ និងចុងចម្លើយអះអាងថា ក្នុងអំឡុងពេលរស់នៅជាមួយគ្នា មានកូនចំនួន០២នាក់ ឈ្មោះ [redacted] **ហ័រអី** ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ និងកូនឈ្មោះ [redacted] **សៀនទ័រ** ភេទប្រុស កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២។

ដើមចោទសុំសិទ្ធិគ្រប់គ្រងកូន ចំណែកឯ ចុងចម្លើយក៏ឯកភាពប្រគល់ឱ្យដើមចោទជាអ្នកមានអំណាចមេបាលើកូនដែរ។ តុលាការយល់ឃើញថា ដើមចោទគឺជាម្ដាយ អាចមានលទ្ធភាពនៅក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យបានល្អ និងគូភាគីបានឯកភាពគ្នាប្រគល់សិទ្ធិអំណាចមេបាឱ្យទៅដើមចោទហើយ ដូចនេះ តុលាការគប្បីសម្រេចប្រគល់សិទ្ធិអំណាចមេបាឱ្យទៅដើមចោទ តាមមាត្រា១០៣៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី។

- **សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្ដាយដែលមិនរស់នៅជាមួយកូន**

ដើមចោទមិនទាមទារអាហារកិច្ចពីចុងចម្លើយទេ តែទោះបីជាយ៉ាងណា ចុងចម្លើយគប្បីផ្ដល់សោហ៊ុយដែលចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនតាមលទ្ធភាព រីឯចុងចម្លើយបានឯកភាពដែរ ដូចនេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី តាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

ដើមចោទដែលមានអំណាចមេបាលើកូនគប្បីសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ភាគីចុងចម្លើយ ក្នុងការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន តាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

- **អំពីទ្រព្យសម្បត្តិរួម និងបំណុលរួម**

ដើមចោទ និងចុងចម្លើយ បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិក) ដែលប្រាក់នេះ គឺខ្ចីដើម្បីយកមកសាងសង់ផ្ទះ ប៉ុន្តែបែរជាចុងចម្លើយយកទៅប្រើការអ្វីផ្សេងទៅវិញ ដូច្នេះ ដើមចោទស្នើសុំឱ្យចុងចម្លើយទទួលរ៉ាប់រងសងប្រាក់ចំនួន ១០,០០០$ ទៅឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ[redacted]វិញ។ រីឯចុងចម្លើយ បានឯកភាពទទួលរ៉ាប់រងបំណុលចំនួន ១០,០០០$(មួយម៉ឺនដុល្លារអាមេរិក) នេះដែរ ។

ដើមចោទសុំសិទ្ធិគ្រប់គ្រងដីមួយកន្លែង ដែលមានទំហំ ១០០ម៉ែត្រការ៉េ ដែលមានទីតាំងនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៨៧២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ រីឯចុងចម្លើយឯកភាព ។ ដូច្នេះ តុលាការយល់ឃើញថា គប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

- ចំពោះប្រាក់ប្រដាប់ក្តី ចុងចម្លើយឯកភាពក្នុងការទទួលរ៉ាប់រង ដូច្នេះគប្បីសម្រេចឲ្យចុងចម្លើយជាអ្នករ៉ាប់រងលើប្រាក់ប្រដាប់ក្តី។

## សេចក្តីសម្រេចបញ្ចប់

ក. ទទួលស្គាល់បណ្តឹងលែងលះរបស់ដើមចោទ។

ខ. ឲ្យភាគីដើមចោទឈ្មោះ [redacted] **ស្រស់** ភេទស្រី កើតថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៨៩ សញ្ជាតិខ្មែរ និងភាគីចុងចម្លើយឈ្មោះ [redacted] **ឈឿន** ភេទប្រុស កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧២ សញ្ជាតិខ្មែរ លែងលះពីគ្នាតាមការព្រមព្រៀង។

គ. ប្រគល់សិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] **ហ័រអី** ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ និងឈ្មោះ [redacted] **សៀនទ័រ** ភេទប្រុស កើតថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ ឲ្យទៅដើមចោទឈ្មោះ [redacted] **ស្រស់** ជាអ្នកចិញ្ចឹម គ្រប់គ្រង បីបាច់ថែរក្សា តាមមាត្រា១០៣៧ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី។

ឃ. បង្គាប់ឲ្យភាគីចុងចម្លើយឈ្មោះ [redacted] **ឈឿន** ផ្តល់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាកូនតាមលទ្ធភាព និងប្រាក់ឧបត្ថម្ភបន្ថែមទៀតតាមលទ្ធភាព ដើម្បីឧត្តមប្រយោជន៍ល្អរបស់កុមារ។ សោហ៊ុយចាំបាច់សម្រាប់បីបាច់ថែរក្សាកូននេះ ត្រូវផ្តល់តាមរយៈលោកស្រី [redacted] **ស្រស់** រហូតដល់កូនមានវ័យនីតិភាព។ លោកស្រី [redacted] **ស្រស់** ត្រូវសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់លោក [redacted] **ឈឿន** ក្នុងការចូលជួបប្រាស្រ័យទាក់ទងជាមួយកូន តាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

ង. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **ឈឿន** ទទួលរ៉ាប់រងបំណុលជំពាក់ [redacted] ចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិក) ។

ច. ប្រគល់ដីមួយកន្លែង ដែលមានទំហំ ១០០ម៉ែត្រការ៉េ មានទីតាំងនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៨០១០១០៣-១៨៧២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ ទៅឱ្យដើមចោទគ្រប់គ្រងជាកម្មសិទ្ធិ ។

ឆ. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

ជ. ទុកសិទ្ធិឱ្យភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទី...... ឆ្នាំ......

ក្រឡាបញ្ជី

[redacted]

[redacted]